# របាយការណ៍ប្រចាំខែមិថុនា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ÷

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷

❖ ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៤ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០៣ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ- ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ÷ ១៨នាក់ |
| – ប្រុស | ÷ ១៤នាក់ |
| – ស្រី | ÷ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ÷ ០៩ នាក់ |
| – ចំនួនកូន | ÷ ១៩ នាក់ |
| – អវត្តមាន | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ | ÷ គ្មាន |

– ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន

– ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន

– ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ ២នាក់

– ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន

– ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ៥នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៤ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | គួន សកល | ប | មន្ត្រី | -កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទដំហានទី៣/៤ (RIP-III/RIPIV) |

### 1.2. ការងារលិខិតចេញ-ចូល

- ***បានធ្វើទទួលលិខិតចូលក្នុងនោះមាន.***
  - លិខិតចូលពីបណ្តាក្រសួង និងអង្គភាពនានាក្រោមន្ទីរចំនួន ÷ ១៨លើក
  - លិខិតចូលពីក្រសួង និងបណ្តារអង្គភាពនានាក្រោមឱវាទមន្ទីរចំនួន ÷១លើក
- ***បានធ្វើលិខិតចេញដែលក្នុងនោះមានៈ***
  - លិខិតចេញទៅបណ្តារអង្គភាពនានក្រៅមន្ទីរចំនួន ÷ ៥លើក
  - លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការចំនួន ÷១០លើក
  - លិខិតចេញទូទៅចំនួន ÷ ០លើក
  - លិខិតចេញទៅក្រសួង និងបណ្តាអង្គភាពនានា ក្រោមឪវាទមន្ទីរចំនួន ÷០លើក
  - លិខិតចេញវិញ្ញាបនប័ត្រវគ្គបណ្តុះបណ្តាលចំនួន ÷០លើក

### 1.3. ការងាររដ្ឋបាល និងបុគ្គលិក

– បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷៣លើក

– បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷១០លើក

– បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷0លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

– បើកប្រាក់បៀវត្សខែឧសភា ជូនមន្ត្រីរាជការ

– ការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ

– បញ្ហាផ្សេងៗ

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

\+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៦** ចំនួន ៥២៣,៥០០,០០០៛០០

– ប្រាក់ជំពូក ៦០ ចំនួន ៧០,០០០,០០០៛

– ប្រាក់ជំពូក ៦១ ចំនួន ១៧១,៥០០,០០០៛

– ប្រាក់ជំពូក ៦៤ ចំនួន ២៨១,០០០,០០០៛

– ប្រាក់ជំពូក ៦៣ ចំនួន ១,០០០,០០០៛

- **ថវិកាចំណាយសម្រាប់ខែមិថុនា ឆ្នាំ២០១៦** ចំនួន ១៨,៥៥០,០០០៛០០

– ប្រាក់ជំពូក ៦០ គ្មាន

– ប្រាក់ជំពូក ៦១ គ្មាន

– ប្រាក់ជំពូក ៦៤ ចំនួន ១៨,៥៥០,០០០៛០០

– ប្រាក់ជំពូក ៦៣ គ្មាន

3. **ការងារផែនការ និងស្ថិតិ** ÷

– ថ្ងៃទី ០៨-០៩ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧-២០១៩ និងការរៀបចំផែនការថវិកាកម្មវិធី សម្រាប់ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាពឯកឧត្តម សៅ ជីវ៉ន រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងមានការចូលរួមពីមន្ត្រីរាជការទាំង២៥ រាជធានី-ខេត្ត នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។

4. **ការងារអធិការកិច្ច និង សវនកម្ម**÷

– គ្មានសកម្មភាព

5. **ការងារទំនាក់ទំនងសាធារណៈ**:

- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការផ្សព្វផ្សាយដំណើរការបច្ចុប្បន្នកម្ម ទិន្នន័យគ្រួសារក្រីក្រឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម មាស រដ្ឋារុឌ្ឍ សមាជិកក្រុមប្រឹក្សាខេត្ត ព្រះវិហារ នៅសាលប្រជុំជាន់ទី ៣ សាលាខេត្តព្រះវិហារ។
- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំការងារបច្ចេកទេសសុខាភិបាលខេត្ត នៅមន្ទីរសុខាភិបាលខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុប ១៧នាក់ ក្នុងនោះស្រី ៨នាក់។

II. **សកម្មភាពការងារតាមវិស័យ ៖**

1. **សកម្មភាពផ្លូវជនបទ**

- ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៦ ចុះពិនិត្យស្ថានភាពកំណាត់ផ្លូវប្រវែង២៣០០ម៉ែត្រ ស្ថិតនៅភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ដែលការ ចូលរួមជាលក្ខណៈអន្តរក្រសួងរួមមាន តំណាងក្រសួង អភិវឌ្ឍន៍ជនបទ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ រៀបចំធ្វើឯកសារ និងធ្វើកំណត់ហេតុ ស្តីពីការចុះពិនិត្យស្ថានភាពផ្លូវ ប្រវែង២៣០០ម៉ែត្រ ស្ថិតនៅភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ញើទៅនាយកដ្ឋាន ផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ២៣-២៤ ខែឧសភា ឆ្នាំ ២០១៦ ចុះត្រួតពិនិត្យការងារជួសជុល និងថែទាំផ្លូវជាលក្ខណៈខួប ប្រវែង១៥ គីឡូម៉ែត្រ ស្ថិតនៅចំនុចចាប់ផ្តើមឃុំស្អាងរហូតដល់ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ។
- ថ្ងៃទី ៩-១០ ខែមិថុនា ឆ្នាំ ២០១៦ បានចុះត្រួតពិនិត្យផ្លូវថែទាំជាលក្ខណៈខួបប្រវែងសរុប ១៥០០០ ម៉ែត្រ ស្ថិតនៅស្រុកជ័យសែន ខេត្តព្រះវិហារ។

2. **សកម្មភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ**

2.1. **ការចុះស្រង់ទិន្នន័យផ្លូវ**

- នៅថ្ងៃទី ១៨-២០ ខែឧសភា ឆ្នាំ ២០១៦ បានចុះស្រង់ទិន្នន័យផ្លូវប្រភេទលេខ ០៣ ចំនួន ០៤ខ្សែ ប្រវែង ៣៣ ៦០០ម៉ែត្រ លូគ្រប់ប្រភេទចំនួន៥០កន្លែង និងស្ពានបេតុងចំនួន ២៤កន្លែង។
- ថ្ងៃទី ១៨-២០ ខែឧសភា ឆ្នាំ ២០១៦ បានចុះស្រង់ទិន្នន័យផ្លូវប្រភេទលេខ០៣ ចំនួន ០៤ខ្សែ ប្រវែង ៣៣ ៦០០ម៉ែត្រ លូគ្រប់ប្រភេទចំនួន៥០កន្លែង និងស្ពានបេតុងចំនួន ២៤កន្លែង។

2.2. **ការងារធ្វើបច្ចុប្បន្នភាព**

- គ្មានសកម្មភាព។

3. **ការងារផ្គត់ផ្គង់ទឹកជនបទ**
   - ថ្ងៃទី ១៧-២១ ខែឧសភា ឆ្នាំ ២០១៦ បានចុះពិនិត្យ និងជួសជុលអណ្តូងបានចំនួន ៣៦ អណ្តូង ដែលស្ថិតនៅក្នុង១៨ភូមិ ០៦ឃុំ នៅស្រុកគូលែន។
   - ថ្ងៃទី ១-២ ខែមិថុនា ឆ្នាំ ២០១៦ បានជួសជុលអណ្តូងបានចំនួន ០២ អណ្តូង ដែលស្ថិតនៅភូមិត្រពាំងទន្ទឹម ឃុំ រមទម នៅស្រុករវៀង។
   - ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៦ បានរៀនចំរបាយការណ៍ពីស្ថានភាពអណ្តូងរីងស្ងួត និងលើកផែនការ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទៅក្រសួងអភិវឌ្ឍនជនបទ។
   - ថ្ងៃទី ៧-១០ ខែមិថុនា ឆ្នាំ២០១៦ បានចូលរៀនវគ្គគ្រូបង្គោលស្តីពី កម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ នៅសាលប្រជុំកបាតក្រហមប្រចាំខេត្តព្រះវិហារ។

4. **ការងារថែទាំសុខភាពជនបទ**
   - បានជូនក្រុមសវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ចុះពិនិត្យមើលបង្គន់អនាម័យថវិកាកម្មវិធីឆ្នាំ ២០១៥ ស្ថិតក្នុងឃុំថ្មី ស្រុកគូលែន និងឃុំរក្សា ស្រុករវៀង។

5. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷**
   - គ្មានសកម្មភាព។

6. **ការងារអភិវឌ្ឍន៍សហគមន៍÷**
   - ថ្ងៃទី ១៦-១៧ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំរអាង ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ៣៦នាក់ ស្រី ១៥នាក់ ដោយមានការចូលរួមគាំទ្រ ដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
   - ថ្ងៃទី ១៨-១៩ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាល ដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំភ្នំត្បែង១ ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ១៨នាក់ ស្រី ០៨នាក់ ដោយមានការចូលរួមគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
   - ថ្ងៃទី ២៥-២៦ ខែឧសភា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅឃុំស្ពោ ស្រុក សង្គមថ្មី ខេត្តព្រះវិហារ មានចំនួន០៥គឺ ភូមិសុច ភូមិស្ពោ ភូមិ ត្រពាំងខ្នែង ភូមិត្រពាំងធ្លក និងភូមិតាបស់ សមាសភាពចូលរួមមាន ចំនួន ៣៥ នាក់ ស្រី ១៥នាក់។

- ថ្ងៃទី ២៧-២៨ ខែឧសភា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅឃុំរណសិរ្ស ស្រុក សង្គមថ្មី ខេត្តព្រះវិហារ មានចំនួន ០៦ គឺ ភូមិសុច ភូមិតាសែងកណ្តាល ភូមិតាសែងជើង ភូមិស្វាយ ត្រពាំងវាំង រលំឡែង និងភូមិគោកថ្កូវ សមាសភាពចូលរួមមាន ចំនួន ៤១ នាក់ ស្រី ១០ នាក់។

7. **ការងារសេដ្ឋកិច្ចជនបទ÷**
   - គ្មានសកម្មភាព។

8. **ការងារជនជាតិដើមភាគតិច÷**
   - នៅថ្ងៃច័ន្ទ ទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពី គោលការណ៍ បង្កើតក្រុមការងារតំណាងជនជាតិភាគតិចនៅតាមខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ុក រ៉ាប៊ុន** នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

9. **ការងារយេនឌ័រ÷**
   - គ្មានសកម្មភាព។

10. **គម្រោង / កម្មវិធី ÷**

10.1. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍ (គាំទ្រថវិកាដោយ** UNICEF)

- ថ្ងៃទី ៧-១០ ខែមិថុនា ឆ្នាំ ២០១៦ បានចូលរួមក្នុងវគ្គកសាងសមត្ថភាពមន្ត្រីបច្ចេកទេស ស្តីពីការអនុវត្តកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ រៀបចំដោយនាយកដ្ឋានថែទាំសុខភាពជនបទ និងមានការគាំទ្រថវិកាដោយអង្គការយូនីសេហ្វ នៅសាលប្រជុំ សាខាកាកបាទក្រហមខេត្តព្រះវិហារ អ្នកចូលរួមសរុបប្រមាណ៤២នាក់ ក្នុងនោះស្រី១២នាក់ មកពីតាមបណ្តាខេត្តទាំង ៥ គឺព្រះវិហារ ស្ទឹងត្រែង រតនគីរី ក្រចេះ និងមណ្ឌលគីរី។

10.2. **ការងារគាំទ្រដោយ** NGOs

- នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្តីពីកម្មវិធីទឹកស្អាតជាមួយអង្គការ ACTION AGAINST HUNGER ប្រចាំខេត្តព្រះវិហារ។
- នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៦ ចុះវាស់ស្រះសហគមន៍ នៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំពិភាក្សាជាមួយអង្គការ ACTION AGAINST HUNGER ពាក់ព័ន្ធលើការប្រើប្រាស់ទឹកស្អាត និង អនាម័យ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ។

- នៅថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៦ ប្រជុំគណៈកម្មការសម្របសម្រួលគម្រោង រៀបចំដោយ ADDRA មានការចូលរួមពីមន្ទីរវិស័យពាក់ព័ន្ធគម្រោងខេត្តកំពង់ធំ ព្រះវិហារ ស្រុក ឃុំ នៅសាលប្រជុំនៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តព្រះវិហារ។
- នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ មន្ត្រីជំនាញផ្គត់ផ្គង់ទឹកជនបទ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ គម្រោងលើកកម្ពស់ជីវភាព របស់ប្រជាពលរដ្ឋនៅជនបទ របស់អង្គការ CWS នៅសាលប្រជុំកបាត ក្រហម ប្រចាំខេត្តព្រះវិហារ។
- ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយពីគម្រោង "លើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជានៅជនបទ" នៅសាលប្រជុំសាខាកាកបាទក្រហមខេត្តព្រះវិហារ រៀបចំដោយអង្គការ ស៊ីដាប់បែលយូអេស។
- នៅថ្ងៃទី ១១-១២ ខែមិថុនា ឆ្នាំ ២០១៦ បានជួសជុលអណ្តូងបានចំនួន០៨អណ្តូង (ឃុំគូលែនជើងបាន ៥អណ្តូង និងគូលែនត្បូងបាន ៣អណ្តូងស្នប់) ដែលសហការជាមួយអង្គការទស្សនៈពិភពលោកស្រុកគូលែន។
- នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ មន្ត្រីជំនាញផ្គត់ផ្គង់ទឹកជនបទ បានចូលរួមប្រជុំពិភាក្សាជាមួយអង្គការ ACTION AGAINST HUNGER ការចុះវាស់វែងស្រះ នៅឃុំយាង និងឃុំកន្ទួត នៅទីរួមខេត្តព្រះវិហារ៕